# សន្ទស្សន៍នៃការយល់ឃើញពី អំពើពុករលួយ ឆ្នាំ២០១៧

TRANSPARENCY INTERNATIONAL
the global coalition against corruption

ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ ១៨:00 GMT

**ដាក់ពិន្ទុ និងចំណាត់ថ្នាក់ឱ្យប្រទេស និងដែនដីចំនួន១៨០ នៅទូទាំងពិភពលោក ទៅលើការយល់ឃើញពីកម្រិតនៃ អំពើពុករលួយក្នុងវិស័យសាធារណៈ**

TRANSPARENCY INTERNATIONAL
the global coalition against corruption

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយគឺជា៖

| | |
|---|---|
| សន្ទស្សន៍ដែលផ្សំបញ្ចូលគ្នា | (ប្រភពទិន្នន័យ១៣ផ្សេងៗគ្នា) |
| មានលក្ខណៈជាសកល | (១៨០ប្រទេស/ដែនដី) |
| វាស់ស្ទង់ការយល់ឃើញ | (អ្នកជំនាញ/ធុរៈជន) |
| ពីអំពើពុករលួយ | (ការប្រើប្រាស់អំណាចខុសច្បាប់ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន) |
| នៅក្នុងវិស័យសាធារណៈ | (មន្ត្រី និងស្ថាប័នសាធារណៈ) |

# វិធីសាស្ត្រ



ជំហានទី១ – ជ្រើសរើសប្រភពទិន្នន័យ

ជំហានទី២ – កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ

ជំហានទី៣ – គណនារកមធ្យមភាគ

ជំហានទី៤ – រាយការណ៍ពីភាពមិនច្បាស់លាស់

# ជំហានទី១ – ជ្រើសរើសប្រភពទិន្នន័យ



## លក្ខណៈនៃប្រភពទិន្នន័យដែលអាចប្រើការណ៍បាន៖

ក) ការប្រមូលទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវអាចជឿទុកចិត្តបាន ហើយធ្វើឡើងដោយស្ថាប័នដែលគេទទួលស្គាល់

ខ) វាស់ស្ទង់ការយល់ឃើញពីអំពើពុករលួយក្នុងវិស័យសាធារណៈ

គ) ការសិក្សាបែបបរិវិស័យ

ឃ) អាចប្រៀបធៀបរវាងប្រទេសជាច្រើនបាន

ង) អាចប្រៀបធៀបជាមួយឆ្នាំមុនៗបាន

# ជំហានទី២–កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ



ក ) បំលែងទិន្នន័យ ( ក្នុងករណីចាំបាច់ )

- តួលេខតូច = កម្រិតនៃអំពើពុករលួយខ្ពស់
- តួលេខធំ = កម្រិតនៃអំពើពុករលួយទាប

ខ ) កំណត់ស្តង់ដាទិន្នន័យតាមមាត្រដ្ឋានCPI ( 0-១00 )

- កំណត់យកតួលេខ ៥0 ជាមធ្យមភាគ
- ដោះស្រាយបំរែបំរួលនៃទិន្នន័យដោយកំណត់យក ពិន្ទុអតិបរមា ១00 និងអប្បបរមា 0


ស្អាតស្អំខ្លាំង
100
90
80
70
60
50
40
30
20
10
0
EIU - rescaled data
0
1
2
3
4
EIU - raw data
ពុករលួយ
ខ្លាំង

# ជំហានទី៣ – គណនារកមធ្យមភាគ



យ៉ាងហោចណាស់មានពិន្ទុពីប្រភពចំនួន៣ សម្រាប់ប្រទេសនីមួយៗ

គណនាមធ្យមភាគធម្មតាសម្រាប់ពិន្ទុទាំងនោះ

ប្រភពទិន្នន័យនីមួយៗមានតម្លៃស្មើៗគ្នា

| ប្រទេស X | ពិន្ទុ |
|---|---|
| ធនាគារពិភពលោក | ៥៨ |
| ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេស | ៥៩ |
| គម្រោងយុត្តិធម៌ពិភពលោក | ៦១ |

ពិន្ទុរបស់ប្រទេស X = ( ៥៨+៥៩+៦១ )/៣

= ៥៩

# ជំហានទី៤– រាយការណ៍ពីភាពមិនច្បាស់លាស់



## ដើម្បីចាប់យកចំនុចមិនច្បាស់លាស់ក្នុងពិន្ទុគឺត្រូវ៖

- គណនាវិធីដែលដោះស្រាយបម្រែបម្រួលនៃទិន្នន័យ
- រាយការណ៍ពីកម្រិតលម្អៀង
- គណនានូវចន្លោះតួលេខដែលគួរឱ្យទុកចិត្ត ៩0%

| ប្រទេស X | ពិន្ទុ |
|---|---|
| ធនាគារពិភពលោក | ៥៨ |
| ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេស | ៥៩ |
| គម្រោងយុត្តិធម៌ពិភពលោក | ៦១ |

ចំនុចលម្អៀងរបស់ប្រទេស X = $\frac{\sqrt{var(58,59,61)}}{\sqrt{3}}$

= 0.85

ចន្លោះតួលេខដែលគួរឱ្យទុកចិត្ត ៩0% = ៥៨ ( ឬទាបជាង )

៦0 (ឬខ្ពស់ជាង)

# ការបកស្រាយលទ្ធផល

TRANSPARENCY INTERNATIONAL
the global coalition against corruption

## ពិន្ទុ៖

នៅលើមាត្រដ្ឋានពី ០ – ១០០ ដែល ០ មានន័យថាអំពើពុករលួយខ្លាំង និង១០០មានន័យថាស្អាតស្អំខ្លាំង។

អនុញ្ញាតឱ្យមានការប្រៀបធៀបជាមួយនឹងពិន្ទុឆ្នាំមុនៗ (២០១៦ ២០១៥ ២០១៤ ២០១៣ ២០១២)៖ ពិន្ទុរបស់ CPI ក្នុងឆ្នាំ២០១៧ អាចប្រៀបធៀបបានជាមួយពិន្ទុ CPI កាលពី៥ឆ្នាំមុន ហើយបម្រែបម្រួលរបស់ពិន្ទុនេះ អាចបកស្រាយបានដោយមានហេតុផលសមស្រប។

## លេខរៀង៖

ក្នុងចំណោមប្រទេស១៨០ទូទាំងពិភពលោក បម្រែបម្រួលលេខរៀងអាចបណ្តាលមកពី៖

ក) ការប្រែប្រួលពិន្ទុCPIសម្រាប់ប្រទេសណាមួយរវាងឆ្នាំ២០១៧ និង ២០១៦

ខ) ការប្រែប្រួលពិន្ទុរបស់ប្រទេសផ្សេងទៀតដែលរួមបញ្ចូលនៅក្នុងសន្ទស្សន៍CPI

គ) ការបន្ថែមចំនួនប្រទេស និងដែនដីនៅក្នុងសន្ទស្សន៍

# ការបកស្រាយលទ្ធផល

TRANSPARENCY INTERNATIONAL
the global coalition against corruption

## ភាពមិនច្បាស់លាស់៖

**ចំនួនប្រភពទិន្នន័យ៖** ចន្លោះពី ៣ (អប្បបរមា) ទៅ ១៣ (អតិបរមា)

**អតិបរមា/អប្បបរមា៖** ផ្តោតលើចន្លោះនៃពិន្ទុដែលប្រភពទិន្នន័យទាំងអស់បានផ្តល់ឱ្យទៅប្រទេសនីមួយៗ

**កម្រិតលម្អៀង៖** ការគណនារបាយពិន្ទុនៃទិន្នន័យ ដោយគិតទាំងចន្លោះនៃទិន្នន័យរបស់ប្រភពនីមួយៗ ហើយនិងចំនួនទិន្នន័យមានសម្រាប់ប្រទេសនោះ

**ចន្លោះជឿជាក់ ៩០%៖** កំណត់លើភាពមិនច្បាស់លាស់នៅក្នុងពិន្ទុCPI តាមរយៈការផ្តល់នូវចន្លោះពិន្ទុមួយដែលយើងអាចទុកចិត្តបាន៩០% ថាពិន្ទុសន្ទស្សន៍CPIនឹងនៅចន្លោះនោះ

# ប្រភពទិន្នន័យសម្រាប់ប្រទេសកម្ពុជា

TRANSPARENCY INTERNATIONAL
the global coalition against corruption

១. សន្ទស្សន៍នៃបម្រែបម្រួលរបស់មូលនិធិ Bertelsmann ឆ្នាំ២០១៧-២០១៨

២. ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសរបស់ទីភ្នាក់ងារសេដ្ឋវិទូ ឆ្នាំ២០១៧

៣. ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្តីពីការយល់ដឹងជាសកល ឆ្នាំ២០១៦

៤. ទីភ្នាក់ងារប្រឹក្សាហានិភ័យនយោបាយ និងសេដ្ឋកិច្ចទ្វីបអាស៊ី ឆ្នាំ២០១៧

៥. ការវាយតម្លៃស្ថាប័ន និងគោលនយោបាយប្រចាំប្រទេសរបស់ធនាគារពិភពលោកឆ្នាំ២០១៧

៦. ការស្ទង់មតិពីធុរៈជនរបស់វេទិកាសេដ្ឋកិច្ចពិភពលោក (EOS) ឆ្នាំ២០១៧

៧. សន្ទស្សន៍ស្តីពីនីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក ឆ្នាំ២០១៧-២០១៨

៨. គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ (VDEM) ឆ្នាំ២០១៧